VOLUNTEER SERVICES

# សេវាកម្មស្ម័គ្រចិត្ត

**តើអ្នកកំពុងស្វែងរកបទពិសោធន៍ការងារស្ម័គ្រចិត្តដែលមានន័យមែនទេ ?**

**តើអ្នកពេញចិត្តធ្វើការជាមួយកុមារឬទេ ?**

**តើអ្នកចង់ជួយជនចាស់ជរាដែលស្នាក់នៅតែក្នុងផ្ទះ អោយពួកគាត់អាចរក្សាបាននូវភាពម្ចាស់ការដែរឬទេ ?**

**ប្រសិនបើអ្នកឆ្លើយថា បាទ/ចាស់ចំពោះសំណួរខាងលើ CTI អាចជួយអ្នកបាន ។**

**កម្មវិធីជីដូន/ជីតាចិញ្ចឹម** : ជីដូន/ជីតាចិញ្ចឹមចំណាយពេលវេលារបស់ខ្លួន ក្នុងសាលារៀន មជ្ឈមណ្ឌលថែទាំ កម្មវិធី ក្រោយម៉ោងសិក្សា និងក្នុងមជ្ឈមណ្ឌល Head Start ។ អ្នកស្ម័គ្រចិត្តទាំងនេះ ជួយកុមារដែលត្រូវការជំនួយ និងការ យកចិត្តទុកដាក់បន្ថែម ដើម្បីអោយកុមារទាំងនេះ អាចធំលូតលាស់ និងទទួលបានជោគជ័យ ។ អ្នកស្ម័គ្រចិត្តទទួលបាន ការធានារ៉ាប់រងលើគ្រោះថ្នាក់ និងបំណុលក្នុងពេលបំពេញការងារ ការទូទាត់ចំណាយលើការធ្វើដំណើរ វត្ថុហ៊ីកហ៊ឺនប្រចាំ ខែ ពិធីទទួលស្គាល់ជាផ្លូវការប្រចាំឆ្នាំ និងប្រាក់កំរៃចំនួន ២.៦៥ ដុល្លារក្នុងមួយម៉ោង ។

**លក្ខខណ្ឌតំរូវ** : អ្នកស្ម័គ្រចិត្តត្រូវមានអាយុចាប់ពី ៦០ ឆ្នាំ និងត្រូវធ្វើការពី ១៥ ទៅ ៤០ ម៉ោងក្នុងមួយសប្តាហ៍ ។

**កម្មវិធីអ្នកថែទាំមនុស្សចាស់** - អ្នកថែទាំមនុស្សចាស់ផ្តល់ការយកចិត្តទុកដាក់ និងការគាំទ្រដល់មនុស្សចាស់ ដែល ត្រូវការជំនួយជាពិសេស ។ អ្នកថែទាំមនុស្សចាស់ ជួយទិញគ្រឿងឧបភោគ-បរិភោគ បើកបរជូនទៅជួបវេជ្ជបណ្ឌិតតាម ការណាត់ ឆ្លើយអ៊ីម៉ែល និងធ្វើការងារប្រចាំថ្ងៃដទៃទៀត ដែលចាំបាច់ក្នុងការរក្សាបាននូវភាពម្ចាស់ការសំរាប់មនុស្ស ចាស់ទាំងនោះ ។ ពួកគេក៏ជួយផ្តល់នូវការសំរាលបន្ទុករយៈពេលខ្លីសំរាប់អ្នកមើលថែសំខាន់ៗ ដូចជា សមាជិកគ្រួសារជា ដើម ។ អ្នកស្ម័គ្រចិត្ត ទទួលបានការធានារ៉ាប់រងលើគ្រោះថ្នាក់ និងបំណុលក្នុងពេលបំពេញការងារ ការទូទាត់ចំណាយលើ ការធ្វើដំណើរ វត្ថុហ៊ីកហ៊ឺនប្រចាំខែ ពិធីទទួលស្គាល់ជាផ្លូវការប្រចាំឆ្នាំ និងប្រាក់កំរៃចំនួន ២.៦៥ ដុល្លារ ក្នុងមួយម៉ោង ។

**លក្ខខណ្ឌតំរូវ** : អ្នកស្ម័គ្រចិត្តត្រូវមានអាយុចាប់ពី ៦០ ឆ្នាំ និងត្រូវធ្វើការ ២០ ម៉ោងក្នុងមួយសប្តាហ៍ ។

**កម្មវិធីអ្នកស្ម័គ្រចិត្តដែលចូលនិវត្តន៍** - អ្នកស្ម័គ្រចិត្តរបស់កម្មវិធីនេះ មានឱកាសបំពេញសេវាកម្មស្ម័គ្រចិត្តជាច្រើន ប្រភេទ តាមការជ្រើសរើសរបស់ខ្លួន ។ ពួកគេអាចរៀបចំកម្មវិធីមើលទូរទស្សន៍ជាមួយអ្នកជិតខាង បង្រៀនកុមារ តុបតែងកែលំអផ្ទះ បង្រៀនភាសាអង់គ្លេសដល់ជនអន្តោប្រវេសន៍ ជួយជនរងគ្រោះដោយសារគ្រោះធម្មជាតិ និងបំរើ សហគមន៍របស់ខ្លួនតាមមធ្យោបាយដទៃទៀតជាច្រើន ។ អ្នកស្ម័គ្រចិត្តមិនទទួលបានប្រាក់កំរៃឡើយ ប៉ុន្តែអង្គការដែល ផ្តល់ការឧបត្ថម្ភ អាចទូទាត់សងអោយពួកគេវិញនូវចំណាយមួយចំនួន ដូចជា ចំណាយធ្វើដំណើរជាដើម ។ តាមរយៈ កម្មវិធីនេះ អ្នកស្ម័គ្រចិត្តច្រើនជាង ៤៨០.០០០ នាក់ហើយនៅទូទាំងប្រទេស បានបំរើសេវាដល់ក្រុមមិនស្វែងរកប្រាក់ ចំណេញក្នុងស្រុក និងតាមមូលដ្ឋានចំនួនប្រហែល ៦៥.០០០ ក្រុម កន្លែងសក្ការៈបូជា និងទីភ្នាក់ងាររដ្ឋាភិបាលនានា ។

**លក្ខខណ្ឌតំរូវ** : អ្នកស្ម័គ្រចិត្តត្រូវមានអាយុ ៥៥ ឆ្នាំ ឬចាស់ជាងនេះ និងគ្មានកំរិតលើប្រាក់ចំណូលឡើយ ។ អ្នកស្ម័គ្រចិត្ត អាចបំរើសេវាកម្ម ២ ឬ ៣ ម៉ោង ដល់ ៤០ ម៉ោងពេញក្នុងមួយសប្តាហ៍ ។

**កម្មវិធីស្ម័គ្រចិត្តជ្រោមជ្រែងពន្ធលើប្រាក់ចំណូល** (VITA) - ការជួយក្រុមគ្រួសារដែលមានចំណូលទាបអោយ ទទួលបាន **ឥណទានពន្ធលើប្រាក់ចំណូល** ដែលពួកគេគួរទទួលបាន ជារឿងដែលអ្នកស្ម័គ្រចិត្តក្នុងកម្មវិធី VITA ធ្វើបានល្អ បំផុត ។ អ្នកស្ម័គ្រចិត្ត ផ្តល់ការជ្រោមជ្រែងលើការរៀបចំរបាយការណ៍លើប្រាក់ចំណូលជាមូលដ្ឋាន និងជួយផ្ញើរបាយការណ៍ តាមប្រព័ន្ធអេឡិចត្រូនិកដោយឥតគិតថ្លៃ ដើម្បីធានាថាបុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ទទួលបាន**ឥណទានពន្ធ លើប្រាក់ចំណូលដែលរកបាន** ។

**លក្ខខណ្ឌតំរូវ** : អ្នកស្ម័គ្រចិត្តត្រូវបញ្ចប់វគ្គបណ្តុះបណ្តាលដែលផ្តល់ដោយ IRS ។

សំរាប់ព័ត៌មានបន្ថែមអំពីកម្មវិធីស្ម័គ្រចិត្តទាំងនេះ សូមទូរស័ព្ទមកលេខ (៩៧៨) ៦៥៤-៥០៨០ លេខភ្ជាប់ ១៤ ឬ ២០។